archive.today
webpage capture
Saved from https://www.vodkhmer.news/2020/04/20/factory-workers-kandal-province-bos search
no other snapshots from this url
16 May 2024 06:45:35 UTC
All snapshots from host www.vodkhmer.news
Webpage Screenshot
share download .zip report bug or abuse



# កម្មកររោងចក្រមួយនៅខេត្តកណ្ដាលថា ថៅកែអនុញ្ញាតឱ្យពួកគេធ្វើការវិញបន្ទាប់ពីមានគម្រោងបញ្ឈប់ដោយសារទៅចូលឆ្នាំ

ព័ត៌មានជាតិ ការងារ កូវីដ-១៩

លោក យុគ សុគន្ធ | ២០ មេសា ២០២០ ម៉ោង ១៧:៥៤




កម្មករ-កម្មការិនី ដែលទើបត្រលប់មកពីស្រុកក្រោយចូលឆ្នាំខ្មែរ ធ្វើតេស្ត និងអនុវត្តវិធានការចត្តាឡីស័ក នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០។ (ផន ចាន់រ៉េន)

កម្មករមួយចំនួនបម្រើការងារនៅរោងចក្រ ប៊ូវឃ័រ (Bowker) ស្ថិតក្នុងស្រុកអង្គស្នួល ខេត្តកណ្ដាល ត្រូវបានថៅកែអនុញ្ញាតឱ្យបម្រើការងារវិញ ក្រោយពីពួកគាត់ត្រូវបង្ខំឱ្យលាឈប់ពីការងារដោយសារទៅចូលឆ្នាំ។

កាលពីសប្ដាហ៍មុន កម្មការិនីមួយចំនួនបម្រើការងារនៅរោងចក្រ ប៊ូវឃ័រ (Bowker) ស្ថិតតាមបណ្ដោយផ្លូវជាតិលេខ៤ ក្នុងឃុំបែកចាន ស្រុកអង្គស្នួល ត្រូវថៅកែបញ្ឈប់ពីការងារ ក្រោយពួកគេត្រលប់ពីចូលឆ្នាំ ហើយមកបំពេញការងារវិញ ប៉ុន្តែ នៅថ្ងៃនេះ កម្មករទាំងនោះអះអាងថា ពួកគេត្រូវបានរដ្ឋបាលរោងចក្រហៅឱ្យបម្រើការងារវិញហើយនៅថ្ងៃទី៣០ ខែមេសា។

កម្មការិនីផ្នែកត្រួតពិនិត្យ (QC) ម្នាក់ អ្នកស្រី ឃុំ វ៉ាន់ ប្រាប់វីអូឌីថា រសៀលម៉ោង ៣ថ្ងៃនេះ រដ្ឋបាលរោងចក្របានទូរសព្ទប្រាប់ឱ្យអ្នកស្រីទៅជួប និង

ប្រាប់ឱ្យអ្នកស្រីចូលបំពេញការងារវិញនៅថ្ងៃទី៣០ ខែមេសា ក្រោយពីដាក់អ្នកស្រីនៅដាច់ឡែកដោយក្នុងបន្ទប់ស្នាក់នៅរយៈពេល ១៤ថ្ងៃ។

> “ អ្នកស្រីបន្ថែមថា៖ «ឥលូវខ្ញុំសប្បាយចិត្តវិញហើយ។ ព្រោះខ្ញុំទទួលបានការងារធ្វើវិញហើយ។ យើងអាចទទួលបានលុយវិញហើយ។ ពីមុនយើងដេកពិបាកចិត្តរឿងជំងឺកូវីដផង និងពិបាកចិត្តរឿងអត់លុយសងគេផង។ នៅក្នុងលិខិតហ្នឹង ខាងរដ្ឋបាលគេឱ្យចូលថ្ងៃទី៣០។ ឥលូវគេឱ្យខ្ញុំនៅបន្ទប់ជួល ១៤ថ្ងៃសិន»។

កម្មការិនីផ្នែកតុកាត់ អ្នកស្រី ភុច សុនី ដែលត្រូវបានថៅកែបញ្ឈប់ពីការងារដោយសារទៅចូលឆ្នាំដែរនោះ ប្រាប់វីអូឌីថា អ្នកស្រីក៏ត្រូវបានរដ្ឋបាលរោងចក្រទូរសព្ទប្រាប់ឱ្យចូលទៅបំពេញការងារវិញ នៅថ្ងៃទី៣០ ខែមេសាដែរ។

កម្មការិនីរូបនេះលើកឡើងថា ប្រសិនបើថៅកែមិនអនុញ្ញាតឱ្យបំពេញការងារវិញទេ គ្រួសារអ្នកស្រីនឹងជួបបញ្ហាជីវភាពធ្ងន់ធ្ងរ ដោយពុំមានលុយបង់សងធនាគារ និងគ្មានលុយសម្រាប់ចំណាយក្នុងគ្រួសារជាដើម។

> “ អ្នកស្រីបន្ថែមថា៖ «ពួកខ្ញុំជាកម្មករចង់ឱ្យខាងក្រសួងការងារពិនិត្យមើលរឿងនេះឡើងវិញ។ ជួយឱ្យពួកខ្ញុំបានធ្វើការងារវិញ។ ព្រោះពួកខ្ញុំជាកម្មករហ្នឹង មិនចង់ឈប់ពីការងារទេ។ យើងចង់ឱ្យរោងចក្រអនុវត្តដែលបានប្រជុំកន្លងមកថា ប្រសិនបើឈប់ គេដាក់ដាច់ដោយឡែក ១៤ថ្ងៃដោយអត់ប្រាក់ឈ្នួល ក៏យើងព្រមដែរ ឱ្យតែបានការងារធ្វើវិញ»។

ប៉ុន្តែ យ៉ាងណា ប្រធានផ្នែកធនធានមនុស្ស នៃរោងចក្រ ប៊ូវឃ័រ (Bowker) លោក សៀង រដ្ឋា សុំមិនឆ្លើយបញ្ជាក់ពាក់ព័ន្ធករណីនេះទេ រង់ចាំសួរយោបល់ពីថ្នាក់លើសិន។

ប្រធានសម្ព័ន្ធសហជីពកម្ពុជា អ្នកស្រី យ៉ាង សុភ័ណ្ឌ ឱ្យដឹងថា តាមព័ត៌មានដែលអ្នកស្រីទទួលបាន នៅរោងចក្រ ប៊ូវឃ័រ (Bowker) មានកម្មករប្រហែល ៤០នាក់ ដែលត្រូវបានថៅកែបង្ខំឱ្យលាឈប់ពីការងារ។ អ្នកស្រីបន្តថា វាជារឿងល្អមួយ ប្រសិនបើថៅកែរោងចក្រនេះ អនុញ្ញាតឱ្យកម្មករបានចូលបម្រើការងារវិញនោះ។

មេសហជីពរូបនេះ ស្នើទៅក្រសួងការងារត្រូវជួយសម្របសម្រួលដោះស្រាយដល់កម្មករនៅរោងចក្រផ្សេងៗទៀតផងដែរ ដែលកំពុងត្រូវបានថៅកែបញ្ឈប់ពីការងារក្រោមហេតុផលមិនគោរពតាមសេចក្ដីណែនាំរបស់រដ្ឋាភិបាល ដើម្បីគេចវេសពីការទូទាត់សំណងផ្សេងៗនោះ។

> “ អ្នកស្រីបន្ថែមថា៖ «យើងសង្ឃឹមថា រដ្ឋាភិបាលក៏ដូចជាក្រសួងការងារព្យាយាមក្នុងការដោះស្រាយបញ្ហាទាំងអស់នេះ ធ្វើយ៉ាងណាកុំឱ្យជ្រុលសហួសហេតុនៃការយកលេសរបស់ក្រុមហ៊ុនក្នុងការគុំកួនទៅលើបងប្អូនកម្មករដោយចេតនា។ ក្រុមហ៊ុនចង់បិទ ឬក៏ចង់ព្យួរការងារ គឺធ្វើឱ្យថៅកែហ្នឹងរួចកាតព្វកិច្ចក្នុងការគិតគូរទូទាត់លុយជូនបងប្អូនកម្មករ»។

កាលពីថ្ងៃទី១៧ ខែមេសា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានចេញសេចក្ដីណែនាំមួយប្រាប់ទៅម្ចាស់រោងចក្រ សហគ្រាស និងកម្មករទាំងអស់ដែលឈប់សម្រាកអំឡុងចូលឆ្នាំ ហើយត្រឡប់មកបំពេញការងារ អនុវត្តវិធានការចត្តាឡីស័ក ដោយដាក់នៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ មុនចូលបំពេញការងារ។

ក្នុងសេចក្ដីណែនាំដដែលនេះ ក្រសួងការងារព្រមានពីការបាត់បង់ការងារធ្វើ និងមិនទទួលបានសំណងចំពោះកម្មករណាដែលមិនគោរពសេចក្ដីណែនាំរបស់ក្រសួងអំពីវិធានការបង្ការជំងឺកូវីដ១៩។

អ្នកនាំពាក្យរបស់ក្រសួងការងារ លោក ហេង សួរ បានបង្ហោះសារលើហ្វេសប៊ុក (Facebook) របស់លោកអំឡុងខែមេសានេះថា បើកម្មករណាឈប់សម្រាកពីការងារនៅថ្ងៃចូលឆ្នាំ អាចចាត់ទុកថា បានប្រព្រឹត្តកំហុសធ្ងន់ ហើយក្រុមហ៊ុនអាចបញ្ឈប់ការងារដោយមិនបាច់ទូទាត់សំណងនោះទេ។

ប្រធានសហភាពការងារកម្ពុជា លោក អាត់ ធន់ មានប្រសាសន៍ថា ការព្រមាន និងវិធានការរបស់ក្រសួងការងារនេះ បានផ្ដល់ឱកាស និងជំរុញឱ្យថៅកែរោងចក្របានលេសបន្ថែមទៀត ដើម្បីបញ្ឈប់កម្មករពីការងារក្នុងអំឡុងពេលអត់ការងារធ្វើ ខណៈដែលរោងចក្រមួយចំនួនកំពុងខ្វះវត្ថុធាតុដើមសម្រាប់ដំណើរការផលិតនោះ។

> “ លោកបន្ថែមថា៖ «ចំពោះកំហិតសំខាន់ដែលថា ក្រុមហ៊ុនអាចបញ្ឈប់កម្មករចោលបាននោះ ខ្ញុំគិតថា កាន់តែធ្វើឱ្យក្រុមហ៊ុនហ្នឹងបញ្ឈប់ចោលកម្មករកាន់តែស្រួលទៅៗ ដោយសារតែក្រុមហ៊ុនមួយចំនួនគាត់រកតែលេសបញ្ឈប់កម្មករចោលអំឡុងពេលអត់មានការងារធ្វើផង។ ហើយបើក្រសួងបើកភ្លើងខៀវឱ្យទៀត ដូចចង់និយាយថា ដូចរកអុសប្រទះឈើងាប់បណ្ដោយ»។

ប៉ុន្តែ យ៉ាងណា សេចក្ដីណែនាំរបស់ក្រសួងការងារ បានឱ្យដឹងថា ចំពោះកម្មករណាដែលឈប់សម្រាកដោយខ្លួនឯងអំឡុងពេលថ្ងៃបុណ្យចូលឆ្នាំ ដោយគ្មានការអនុញ្ញាតពីថៅកែនោះ គឺមិនត្រូវទទួលប្រាក់ឈ្នួលឡើយអំឡុងពេលដាក់ដាច់ដោយឡែក ១៤ថ្ងៃនោះ។

ចំណែកកម្មករដែលឈប់សម្រាកដោយមានការអនុញ្ញាតពីថៅកែ ត្រូវទទួលបានប្រាក់ឈ្នួលតែ ៧ថ្ងៃប៉ុណ្ណោះក្នុងអំឡុងពេលដាក់ដាច់ដោយឡែក ១៤ថ្ងៃ ខណៈកម្មករដែលអវត្តមានដោយមានការអនុញ្ញាតពីថៅកែដោយសារមានធុរៈពិសេស ដូចជា ប្រពន្ធឆ្លងទន្លេ ឬបងប្អូនសាច់ញាតិទទួលមរណភាព ត្រូវទទួលបានប្រាក់ឈ្នួលពេញចំនួន ១៤ថ្ងៃ៕

---

© រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម

សូមបញ្ជាក់ថា គ្មានផ្នែកណាមួយនៃអត្ថបទ រូបភាព សំឡេង និងវីដេអូទាំងនេះ អាចត្រូវបានផលិតឡើងវិញក្នុងការបោះពុម្ពផ្សាយ ផ្សព្វផ្សាយ ការសរសេរឡើងវិញ ឬ ការចែកចាយឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឡើយ។
ស៊ីស៊ីអាយអឹម មិនទទួលខុសត្រូវចំពោះការលួចចម្លងនិងចុះផ្សាយបន្តណាមួយ ដែលខុស នាំឲ្យយល់ខុស បន្លំ ក្លែងបន្លំ តាមគ្រប់ទម្រង់និងគ្រប់មធ្យោបាយ។ ជនប្រព្រឹត្តិ និងអ្នកផ្សំគំនិត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់កម្ពុជា និងច្បាប់នានាដែលពាក់ព័ន្ធ។

## អត្ថបទទាក់ទង

### សូមផ្តល់មតិយោបល់លើអត្ថបទនេះ

នាម និងគោត្តម *

សូមវាយបញ្ចូលឈ្មោះរបស់អ្នក

អ៊ីម៉ែល *

សូមវាយអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក...

លេខទូរសព្ទ (មិនចាំបាច់)

បើសិនជាអ្នកចង់ឱ្យខាងក្រុមការងារ វីអូឌី ទាក់ទងទៅអ្នក សូមទម្លាក់លេខទូរសព្ទ ...

មតិយោបល់ *

សូមបញ្ចូលមតិយោបល់សម្រាប់អត្ថបទខាងលើនេះ...

ចុចបញ្ជូន

## ព័ត៌មានថ្មីៗ | បោះឆ្នោត




លោក ហ៊ុន ម៉ាណែត បដិសេធមិនបានចុះហត្ថលេខាជំនួសនាយករដ្ឋមន្ត្រីរឿងផ្តល់ជំនួយដល់ប្រទេសតួកគីនោះទេ

១២ កុម្ភៈ ២០២៣ ម៉ោង ១៨:១២

ធនាគារជាតិព្រមានវិធានការច្បាប់លើម្ចាស់គ្រឹះស្ថានឥណទានទទួលយកអត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារពីកូនបំណុល



១២ កុម្ភៈ ២០២៣ ម៉ោង ១៣:១៤

ក្រសួងការងារថា ក្រុមហ៊ុន ខេមបូ ហែនសាំ យល់ព្រមទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនកម្មករ




១១ កុម្ភៈ ២០២៣ ម៉ោង ១៦:១៣

អង់គ្លេសសង្ឃឹមថា ការបោះឆ្នោតជាតិខាងមុខនឹងប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងគ្មានការគំរាមកំហែង



ព្រះមហាក្សត្រតែងតាំងសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រលោក សំបូរ មាណ្ណារ៉ា ជាទីប្រឹក្សាលោក ហ៊ុន សែន



១១ កុម្ភៈ ២០២៣ ម៉ោង ១៥:៤១

១១ កុម្ភៈ ២០២៣ ម៉ោង ១៤:៥៣




VOD

VOD គឺជាស្ថាប័នព័ត៌មានឯករាជ្យដែលផ្ដល់ព័ត៌មាន ផលិតកម្មវិធីវិទ្យុ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រអ៊ីនធើណេត។

info@vodhotnews.com

+៨៥៥ ២៣ ៧២៦ ៨៤៥ - លេខបន្ទាន់: +៨៥៥ ៩២ ៩២ ១៩ ០២ / +៨៥៥ ៦០ ៥០ ៥០ ៥០

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

GET IT ON Google Play

Download on the App Store




ស្វែងរកព័ត៌មាន
អំពីយើង
បណ្ណាសាររូបភាព
ព័ត៌មានជាសំឡេង
ក្រមសីលធម៌
ទូរទស្សន៍
VOD ENGLISH
ទំនាក់ទំនង
ទិន្នន័យចាស់ៗ
ឱកាសការងារ

© ២០២២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម